ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ : ៦៩/១៥ ប.ស.ស

*រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥*

# សេចក្តីណែនាំ

## ស្តីពីនីតិវិធី និងបែបបទនៃការចុះបញ្ជិកាកម្មករនិយោជិត មកក្នុងបេឡាជាតិរបបសន្តិសុខសង្គម

អនុលោមតាមប្រការ ៣ថ្មី នៃប្រកាសលេខ ២៨៥ ក.ប/ប្រ.ក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលប្រការ ៣, ប្រការ ៤ និងប្រការ ៥ នៃប្រកាសលេខ ០២១ ក.ប/ប្រ.ក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីបញ្ជិកា សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សូមធ្វើការណែនាំដល់ នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន អំពីនីតិវិធី និងបែបបទនៃការចុះបញ្ជិកាកម្មករនិយោជិតត្រូវបានកែប្រែដូចខាងក្រោម ៖

*ក. ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកានៅ ប.ស.ស*

ក១- ការចុះបញ្ជិកាកម្មករនិយោជិតត្រូវធ្វើតាមទម្រង់ *សលាប័ត្រព័ត៌មាន* សម្រាប់ផ្តល់អត្តសញ្ញាណសមាជិក ប.ស.ស ដូចមានឯកសារជូនភ្ជាប់មក ។

ក២- ប.ស.ស នឹងផ្តល់កាលបរិច្ឆេទសម្រាប់ការចុះកំណត់អត្តសញ្ញាណសមាជិក ប.ស.ស នៅតាមមូលដ្ឋានសហគ្រាស គ្រឹះស្ថាន ។

ក៣- នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចបំពេញព័ត៌មានកម្មករនិយោជិតឲ្យបានត្រឹមត្រូវនៅក្នុង*សលាប័ត្រព័ត៌មាន* ដោយភ្ជាប់មកជាមួយនូវឯកសារដូចជា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន ឬសំបុត្រកំណើត ឬសៀវភៅគ្រួសារ ឬប័ណ្ណស្នាក់នៅ ឬឯកសារផ្សេងៗដែលមានតម្លៃស្មើ ។

ក៤- ប.ស.ស នឹងផ្តល់លេខអត្តសញ្ញាណ និងប័ណ្ណសមាជិក ប.ស.ស ជូនកម្មករនិយោជិតតាមរយៈនិយោជក ឬតំណាង ។

*ខ. ចំពោះសហគ្រាស គ្រឹះស្ថាន ដែលចុះបញ្ជិកាថ្មី*

ខ១- ការចុះបញ្ជិកាកម្មករនិយោជិត ត្រូវធ្វើក្នុងពេលដំណាលគ្នានិងការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន។

ខ២- សហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតចាប់ពី ៥០នាក់ ឡើងទៅ ប.ស.ស នឹងផ្តល់កាលបរិច្ឆេទចុះទៅកំណត់អត្តសញ្ញាណកម្មករនិយោជិត ។ និយោជកត្រូវអនុវត្តកាតព្វកិច្ចដូចមានចែង នៅក្នុងចំណុច ក៣ ខាងលើ។

ខ៣- សហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតក្រោម ៥០នាក់ ប.ស.ស នឹងផ្តល់កាលបរិច្ឆេទ និងអញ្ជើញនិយោជក ឬតំណាង និងកម្មករនិយោជិត មកកំណត់អត្តសញ្ញាណកម្មករនិយោជិតនៅប.ស.ស ដោយភ្ជាប់មកជាមួយនូវឯកសារដូចមានចែងក្នុងចំណុច ក៣ ខាងលើ បន្ទាប់ពីបានបំពេញ*សលាប័ត្រព័ត៌មានរួច* ។

ខ៤- ប.ស.ស នឹងផ្តល់លេខអត្តសញ្ញាណ និងប័ណ្ណសមាជិក ប.ស.ស ជូនកម្មករនិយោជិត តាមរយៈនិយោជក ឬតំណាង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ជានិយោជក និងកម្មករនិយោជិត មេត្តាជ្រាប និងត្រូវមានកាតព្វកិច្ចអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំខាងលើ ដោយស្មារតីទទួលខុសត្រូវចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**នាយកបេឡាជាតិរបបសន្តិសុខសង្គម**

**អ៊ុក_សមវិទ្យា**

*កន្លែងទទួល*

- *ថ្នាក់ដឹកនាំប.ស.ស*
- *គ្រប់ការិយាល័យប.ស.សថ្នាក់កណ្តាល*
- *គ្រប់សាខា ប.ស.សរាជធានី/ខេត្ត*
- *គ្រប់គណៈកម្មការ/ក្រុមការងារចំណុះប.ស.ស ដើម្បីជូនជ្រាប*
- *គ្រប់សហគ្រាស គ្រឹះស្ថាន (សហការអនុវត្ត)*
- *គ្រប់សហព័ន្ធ សហជីព (ផ្សព្វផ្សាយ)*
- *ឯកសារ-កាលប្បវត្តិ*

អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្សី ទូរស័ព្ទ: ០២៣-៨៨ ២៤ ៣៤ , ០២៣ ៩៩ ៨៤ ១៧ ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70

Website : www.nssf.gov.kh